កិច្ចការ១៣:១-៥២

# ជំពូក ១៣

***ដាវចនា*** *បេសកកម្មលើកទីមួយរបស់សាវ័កប៉ុល*
*ពួកជំនុំបញ្ជូនលោកបាណាបាសនិងសាវ័កប៉ុលពីក្រុងអាន់ទីយ៉ូក*
*សកម្មភាពប្រឆាំងនៅកោះប៉ាផុស*
*សាវ័កប៉ុលអធិប្បាយនៅក្រុងអាន់ទីយ៉ូក*

ពេលនេះ យើងចាប់ផ្តើមសិក្សាវគ្គចុងក្រោយបង្អស់នៃកំណួគម្ពីរកិច្ចការ។ ពោល គឺពីជំពូក១៣ដល់ជំពូក២៨។

ព្រះអម្ចាស់ទ្រង់ធ្វើអោយដំណឹងល្អរបស់ព្រះអម្ចាស់យេស៊ូវ រីកជាផ្លូវការទៅដល់ចុងបំផុតនៃផែនដីហើយ។

យើងអរគុណព្រះអង្គ ដែលធ្វើអោយដំណឹងល្អបានរីកសាយទៅដល់ចុងបំផុតនៃផែនដី ដោយបណ្តាលអោយគ្រីស្ទបរិស័ទបានមកផ្សាយដំណឹងល្អ ដល់ស្រុកភូមិរបស់យើង។ បើគ្មានអ្នកទាំងនោះទេ ម្ល៉េះសមយើងមិនបានស្គាល់ព្រះអម្ចាស់យេស៊ូវថាជាអង្គសង្គ្រោះដូចសព្វថ្ងៃនេះឡើយ។ ភារៈរបស់យើងគឺត្រូវនាំដំណឹងល្អទៅដល់ទីណាដែលមិនមានមនុស្សឮពីព្រះនាមព្រះអម្ចាស់យេស៊ូវគ្រីស្ទ។

សាវ័កពេត្រុសបានបញ្ចប់កិច្ចការរបស់លោកហើយ។ ឥឡូវនេះ សាវ័កប៉ុលចូលមកបំពេញតួនាទីជាអ្នកដឹកនាំការងាររបស់ព្រះអង្គម្តង។ ព្រះជាម្ចាស់ប្រើសាវ័កប៉ុលយ៉ាងខ្លាំងក្លា។

សាវ័កប៉ុលចេញទៅបម្រើការងារព្រះអង្គជាបេសកជន រួមជាមួយនឹងលោកបាណាបាស។ លោកសំចតដំបូងបង្អស់នៅកោះគីប្រុស ជាស្រុកកំណើតរបស់លោកបាណាបាស។ លោកនាំគ្នាដើរឆ្លងខ្វងកោះ រួចហើយចុះសំពៅនៅម្តុំប៉ាផុស ដើម្បីឆ្លងទៅស្រុកពើកាក្នុងខេត្តប៉ាមភីលា។ ពីទីនោះ លោកធ្វើដំណើរចូលទៅក្នុងទ្វីបអាស៊ី ចុងខាងលិច ដែលសព្វថ្ងៃនេះ ជាប្រទេសទួរគី។ លោកចូលទៅក្រុងអាន់ទីយ៉ូក អ៊ីកូនាម លីស្ត្រា ឌើបី រួចត្រឡប់មកអាត់តាលីយ៉ា ហើយបង្ហួសមកទីក្រុងអាន់ទីយ៉ូកវិញ។ ទីក្រុងអាន់ទីយ៉ូក មានពីរកន្លែង មួយនៅស្រុកពីស៊ីឌា ហើយមួយទៀត នៅខេត្តស៊ើរី។

## ពួកជំនុំបញ្ជូនលោកបាណាបាស និងសាវ័កប៉ុលពីក្រុងអាន់ទីយ៉ូក

**១ រីឯក្នុងពួកជំនុំនៅក្រុងអាន់ទីយ៉ូក នោះមានគ្រូអធិប្បាយ នឹង**
**គ្រូបង្រៀនខ្លះ គឺបាណាបាស១ ស៊ីម្មាន ដែលហៅថា នីគើរ១**
**លូគាស ជាសាសន៍គីរេន១ ម៉ាន៉ាអេន ជាកូនចិញ្ចឹមជាមួយនឹង**
**ហេរ៉ូឌ ស្តេចអនុរាជ១នឹងសុល១**
**២ កំពុងដែលអ្នកទាំងនោះធ្វើ**

**ការងារ ថ្វាយព្រះអម្ចាស់ទាំងតម នោះព្រះវិញ្ញាណបរិសុទ្ធមាន បន្ទូលប្រាប់ថា ចូរញែកបាណាបាស នឹងសុលចេញឱ្យខ្ញុំ សំរាប់ ការងារដែលខ្ញុំហៅគេឱ្យធ្វើ (កិច្ចការ១៣:១-២)។**

កាលលោកទាំងពីរចាប់ផ្ដើមបម្រើកិច្ចការងាររបស់ព្រះអង្គ លោកបាណាបាសជាអ្នកនាំមុខលោកសុល។ ក្រោយមកបន្ទាប់ពីលោកសុលប្ដូរឈ្មោះទៅជាលោកប៉ុល លោកប៉ុលបានត្រឡប់ជាអ្នកនាំមុខផ្នែកកិច្ចការងារបេសកកម្មនេះវិញ។

**ដូច្នេះ ក្រោយដែលបានតមហើយអធិស្ឋាន ព្រមទាំងដាក់ដៃលើ អ្នកទាំង២ នោះក៏បើកឱ្យគេទៅ (កិច្ចការ១៣:៣)។**

លោកសាវ័កប៉ុល ហើយនិងលោកបាណាបាសត្រូវក្រុមជំនុំតែងតាំងបញ្ជូនធ្វើជាបេសកជនផ្សាយដំណឹងល្អ។ ក្រុមជំនុំនៅទីក្រុងអាន់ទីយ៉ូក ដែលជាក្រុមជំនុំសាសន៍ដទៃ ចេះបញ្ជូនមនុស្សទៅផ្សាយដំណឹងល្អនៅភូមិឯនាយ។ ក្រុមជំនុំទីក្រុងយេរូសាឡិម មិនបានធ្វើបេសកកម្មទេ។ ពួកជំនុំនៅទីក្រុងអាន់ទីយ៉ូកតែងតែនាំគ្នាអធិស្ឋានទាំងតម ពីព្រោះគេចង់ស្គាល់ព្រះហឫទ័យបំណងរបស់ព្រះចំពោះជីវិតរបស់គេ ក៏ដូចជាជីវិតរបស់ក្រុមជំនុំគេដែរ។

អ្នកចាស់ទុំនាំគ្នាដាក់ដៃលើលោកប៉ុល ហើយនិងលោកបាណាបាស ដើម្បីបញ្ជូនធ្វើជាបេសកជនពីក្រុមជំនុំខ្លួន។ សព្វថ្ងៃពេលយើងបញ្ជូនបេសកជនចេញទៅបម្រើព្រះអង្គនៅកន្លែងផ្សេង យើងក៏ត្រូវធ្វើយ៉ាងដូច្នោះដែរ។ ការដាក់ដៃ គឺជាការបញ្ជាក់ថា អ្នកទាំងពីរជាអ្នកចេញទៅផ្សាយដំណឹងល្អ ជំនួសវិហារ ឬក្រុមដែលបញ្ជូនគេទៅ។ អ្នកដែលដាក់ដៃត្រូវអធិស្ឋាន និងត្រូវគាំទ្រកិច្ចការដែលបេសកជននោះត្រូវធ្វើ។ ចំណែកឯបេសកជន ក៏ត្រូវគិតថា ខ្លួនទទួលខុសត្រូវចំពោះអ្នកដែលគេដាក់ដៃបញ្ជូនទៅ។ ពួកជំនុំនៅទីក្រុងអាន់ទីយ៉ូក នាំគ្នាដាក់ដៃលើសាវ័កប៉ុល និងលោកបាណាបាស។ លោកទាំងពីរចេញទៅធ្វើជាអ្នកតំណាងរបស់ក្រុមជំនុំនោះ។ បេសកកម្មរបស់ក្រុមជំនុំត្រូវតែជាកន្លែងដែលនៅឯនាយ គឺកន្លែងដែលពួកជំនុំពិបាកគ្រប់គ្រងការងារផ្សាយដំណឹងល្អ។

**ឯអ្នកទាំង២នោះ ក៏ចុះទៅដល់សេលើស៊ា ដោយព្រះវិញ្ញាណបរិសុទ្ធចាត់ឱ្យទៅ នៅទីនោះគេចុះសំពៅចេញទៅឯកោះគីប្រុស (កិច្ចការ១៣:៤)។**

ព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គនឹងដឹកនាំលោកទាំងពីរ អោយធ្វើដំណើរតាមឆ្នេរសមុទ្រឆ្ពោះទៅកាន់ទីក្រុងសេលើស៊ា រួចហើយចុះសំពៅពីទីក្រុងនោះ។

**ដល់សាឡាមីនហើយ គេក៏ផ្សាយព្រះបន្ទូល នៅក្នុងសាលាប្រជុំទាំងប៉ុន្មានរបស់ពួកសាសន៍យូដា មានទាំងយ៉ូហានជាអ្នកជំនួយដែរ (កិច្ចការ១៣:៥)។**

យុទ្ធវិធីរបស់សាវ័កប៉ុល គឺទីណាដែលលោកទៅ លោកសំដៅទៅសាលាប្រជុំរបស់សាសន៍យូដា។ ពីចំណុចនោះទៅ លោកចេះតែផ្សាយដំណឹងល្អទៅឯសាសន៍ដទៃទៀត។ ឯលោកយ៉ូហាន-ម៉ាកុស ក៏រួមដំណើរជាមួយនឹងលោកទាំងពីរដែរ។

## សកម្មភាពប្រឆាំងនៅកោះប៉ាផុស

**កាលបានដើរកាត់កោះទៅត្រឹមប៉ាផុសហើយ នោះក៏ប្រទះនឹងសាសន៍យូដាម្នាក់ដែលធ្វើ ជាគ្រូអាបធ្មប់ ជាហោរាក្លែងក្លាយ ឈ្មោះបារ-យេស៊ូវ (កិច្ចការ ១៣:៦)។**

សាវ័កប៉ុលនិងលោកបាណាបាស ហាក់ដូចជាមិនសូវទទួលបានជោគជ័យអំពីកិច្ចការរបស់ព្រះអម្ចាស់យេស៊ូវ នៅទីក្រុងសាឡាមីនទេ។ បន្ទាប់មកទៀត លោកធ្វើដំណើរទៅកោះគីប្រុស រួចហើយដើរឆ្លងកោះដើម្បីទៅឯត្រើយម្ខាងទៀត។ នៅស្រុក

ប៉ាផុស លោកជួបជាមួយនឹងសកម្មភាពប្រឆាំង ដែលបង្ករឡើងដោយគ្រូធ្មប់មួយរូប។ គ្រូធ្មប់នោះ ពូកែណាស់ ដ្បិតសូម្បីចៅហ្វាយខេត្តរបស់រាជការរ៉ូម ក៏ស្ថិតនៅក្រោមអំណាចរបស់គ្រូធ្មប់នេះដែរ។

> **[៧]គ្រូនោះនៅជាមួយនឹងអ្នកដំណាងជាតិរ៉ូមម្នាក់ ឈ្មោះសើគាស-ប៉ូល្ល៉ុស ជាអ្នកឆ្លៀវឆ្លាត លោកក៏ហៅ បាណាបាស នឹងសុលមក ដើម្បីចង់ស្ដាប់ព្រះបន្ទូល [៨]តែអេលីម៉ាស ជាគ្រូអាបធ្មប់នោះ (ដ្បិតឈ្មោះនោះប្រែមកដូច្នេះ) ក៏តាំងខ្លួនទាស់នឹងគេ ដើម្បីបង្វែរលោកមិនឱ្យជឿ (កិច្ចការ១៣:៧-៨)។**

ការប្រឆាំងនេះ កើតដោយសារសាតាំងផ្ទាល់តែម្តង។ ចៅហ្វាយខេត្តស្រុកនោះ ឈ្មោះសើគាស-ប៉ូល្ល៉ុស។ លោកតែងតែសួរយោបល់ដល់គ្រូធ្មប់នេះជានិច្ចក្នុងការគ្រប់គ្រងដល់ប្រជាពលរដ្ឋ។ សព្វថ្ងៃមានអ្នកដឹកនាំនគរច្រើនណាស់ ដែលស្ថិតនៅក្រោមអំណាចគ្រូមន្តអាគម។ លុះដំណឹងល្អបានឈានទៅដល់ទីណា គ្រូមន្តអាគមចេះតែចាក់រុកដល់អ្នកដឹកនាំរបស់នគរ មិនអោយព្រះបន្ទូលរបស់ព្រះអង្គធ្វើអោយមនុស្សសុចរិតបានដុះដាលកើតទេ។

> **តែសុលដែលហៅថា ប៉ុលដែរ គាត់បានពេញជាព្រះវិញ្ញាណបរិសុទ្ធ ក៏សំឡឹងមើលទៅគ្រូនោះ ដោយនិយាយថា (កិច្ចការ ១៣:៩)។**

ក្នុងពេលនេះ លោកសុលបានប្ដូរឈ្មោះរបស់លោកមកជាប៉ុលវិញ។ តើប៉ុលមានន័យយ៉ាងដូចម្ដេច? លោកប៉ុលប្រែថា មាឌតូចល្អិត។ អ្នកខ្លះយល់ថា លោកមិនចង់ប្រើឈ្មោះសុលដូចមុនទៀតទេ ពីព្រោះសុលជាអ្នកមានអំណាចខ្លាំងក្លាហួសហេតុពេក។ លោកចង់ដាក់ឈ្មោះប៉ុលវិញ ពីព្រោះមានន័យថា ល្អិតល្អោច។

> **នែ មនុស្សដែលពេញដោយកិច្ចកល នឹងសេចក្ដីល្បិចគ្រប់យ៉ាង ជាកូននៃអារក្ស ហើយជាខ្មាំងសត្រូវ ដល់គ្រប់ទាំងសេចក្ដីសុចរិតអើយ តើមិនព្រមឈប់បង្ខូចផ្លូវត្រង់របស់ព្រះអម្ចាស់ទេឬអី (កិច្ចការ១៣:១០)។**

កន្លងមកសាវ័កប៉ុលនិយាយស្ដីដោយថ្នាក់ថ្នមអ្នកស្ដាប់ណាស់។ ប៉ុន្តែនៅពេលដែលគ្រូធ្មប់បានងើបមុខបញ្ចេញសកម្មភាពប្រឆាំងជាមួយនឹងលោក សាវ័កប៉ុលមិនបណ្ដាក់មាត់ទេ។ លោកដឹងច្បាស់ថា អំណាចនេះមកពីសាតាំង។ ដូច្នេះ លោកត្រូវបន្ទោសសាតាំងដោយចេស្ដារបស់ព្រះយេស៊ូវគ្រីស្ទ។ យើងជាអ្នកបម្រើព្រះអង្គ

សព្វថ្ងៃ ត្រូវប្រើអំណាចរបស់ព្រះអម្ចាស់យេស៊ូវ ដើម្បីបន្ទោសដល់កិច្ចការរបស់សាតាំង ដែលឃាត់ឃាំងមិនអោយមនុស្សជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទដែរ។

**មើល ឥឡូវនេះ ព្រះហស្តនៃព្រះអម្ចាស់បានមកលើឯងហើយ ឯងនឹងត្រូវខ្វាក់ភ្នែក មើលមិនឃើញពន្លឺថ្ងៃជាយូរបន្តិច នោះស្រាប់តែភ្នែករបស់គ្រូនោះបានទៅជាព្រិលៗ ហើយងងឹតសូន្យទៅ រួចក៏ដើរវិលវល់រកអ្នកណាឲ្យដឹកដៃ (កិច្ចការ១៣:១១)។**

លោកអេលីម៉ាសដែលជាគ្រូធ្មប់ ស្ថិតនៅក្រោមសំណាញ់ព្រលឹងវិញ្ញាណយ៉ាងខ្មៅងងឹត។ ឥឡូវ រូបកាយរបស់លោកក៏ត្រូវខ្វាក់ងងឹតថែមទៀតផង។

**កាលលោកដំណាងជាតិឃើញការដែលកើតមកដូច្នោះ នោះក៏ជឿ ព្រមទាំងមានសេចក្តីអស្ចារ្យក្នុងចិត្ត អំពីសេចក្តីបង្រៀនរបស់ព្រះអម្ចាស់ផង (កិច្ចការ១៣:១២)។**

ខ្ញុំចង់អោយលោកអ្នកបងប្អូនសង្កេតកិរិយាសាវ័កប៉ុលត្រង់នេះ អោយបានហ្មត់ចត់។ លោកអាចធ្វើទីសម្គាល់បាន ពីព្រោះជាអត្តសញ្ញាណបញ្ជាក់ថា លោកជាមនុស្សដែលព្រះយេស៊ូវគ្រីស្ទបញ្ជូនមក។ នៅពេលដែលលោកសាវ័កប៉ុលធ្វើដំណើរ

ទៅដល់ដំបន់ប៉ាផុស លោកមិនបានយកគម្ពីរសញ្ញាថ្មីទៅជាមួយនឹងខ្លួនទេ។ សម័យនោះ មិនទាន់មានព្រះគម្ពីរសញ្ញាថ្មីនៅឡើយ។ ដូច្នេះ តើធ្វើដូចម្ដេចដើម្បីអោយអ្នកផងទាំងពួងដឹងថា លោកជាមនុស្សដែលព្រះជាម្ចាស់បញ្ជូនមកអោយផ្សព្វផ្សាយដំណឹងល្អ? មនុស្សទទួលស្គាល់ថា លោកជាអ្នកដែលព្រះជាម្ចាស់បញ្ជូនមក ដោយសារទីសម្គាល់ដែលជាអំណោយទានព្រះប្រទានមកអោយលោក។ បច្ចុប្បនេះ យើងមានព្រះគម្ពីរសញ្ញាថ្មីសរសេរជាលាយលក្ខណ៍អក្សរយ៉ាងពេញលេញហើយ។ អំណាចចេស្ដារបស់ព្រះជាម្ចាស់ មិនមែនស្ថិតនៅលើទីសម្គាល់ទៀតទេ។ សព្វថ្ងៃ ចេស្ដារបស់ព្រះជាម្ចាស់ស្ថិតនៅលើព្រះបន្ទូលរបស់ព្រះដែលសរសេរជាភាសាមនុស្សជាតិ។ សាវ័កយ៉ូហានបញ្ជាក់ច្បាស់អំពីចេស្ដារបស់ព្រះបន្ទូលថា "បើអ្នកណាមកឯអ្នករាល់គ្នា តែមិនបង្រៀនចំពោះសេចក្ដីនេះ នោះកុំឱ្យទទួលអ្នកនោះនៅក្នុងផ្ទះឡើយ ក៏កុំឱ្យទាំងជំរាបសួរដល់អ្នកនោះផង" (២យ៉ូហាន១០)។ ព្រះបន្ទូលរបស់ព្រះ ដែលសរសេរឡើងជាភាសាមនុស្សជាតិជាគោលទ្ធិដែលពួកជំនុំសព្វថ្ងៃ ត្រូវយកមកធ្វើជាអំណាចចេស្ដាសម្រាប់គ្រប់គ្រងជំនឿ និងជីវិតរស់នៅរបស់ខ្លួនផ្ទាល់។

នៅភូមិប៉ាផុស គ្រូធ្មប់មួយរូបនេះ ធ្លាប់ប្រើមន្តអាគមធ្វើអោយអ្នកស្រុកបាក់ស្បាត។ ដូចយើងឃើញស្រាប់ហើយថា សព្វថ្ងៃនេះ គ្រូមន្តអាគមក៏ចេះមើលជម្ងឺអោយជាបានដែរ។ ដូច្នេះ ការប្រោសជម្ងឺជា មិនមែនចាំបាច់មកពីព្រះជាម្ចាស់ទេ។ សាតាំងក៏ចេះប្រើអំណាចរបស់វា ធ្វើអោយជម្ងឺបានជាសះស្បើយដែរ។

ចំណែកសាវ័កប៉ុលវិញ អំណាចរបស់លោកទទួលបានមកពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ អំណាចរបស់លោក មានប្រៀបលើអំណាចរបស់គ្រូធ្មប់ ត្រង់ដែលថាសាវ័កប៉ុលមានចេស្ដារបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ដែលទ្រង់រស់ពីសុគតឡើងវិញ។ លោកអភិបាលខេត្តជនជាតិរ៉ូមម្នាក់ នាមសេគាស-ប៉ូល៉ូស បានចូលមកទទួលពន្លឺពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ តាមរយៈលោកប៉ុល។ កន្លងមកលោកស្ថិតនៅក្រោមអំណាចគ្រូធ្មប់ តែឥឡូវនេះ លោកបានត្រឡប់មកជាអ្នកជឿដល់ព្រះអង្គវិញ ពីព្រោះលោកបានឃើញសេចក្ដីអស្ចារ្យនៅក្នុងគោលទ្ធិរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។

**ប៉ុល នឹងពួកគ្នាគាត់ ក៏ចុះសំពៅចេញពីប៉ាផុសទៅដល់ពើកា នៅស្រុកប៉ាមភីលា ឯយ៉ូហាន គាត់បែកពីគេ ត្រឡប់ទៅឯក្រុងយេរូសាឡិមវិញ (កិច្ចការ១៣:១៣)។**

បណ្ឌិតលូកា មិនបានសរសេររឿងអាក្រក់អំពីដំណើរលោកយ៉ូហាន-ម៉ាកុសទេ។ នៅក្នុង៦១៣ លោកយ៉ូហាន-ម៉ាកុសរត់ចោលមិត្តភក្តិ ពេលដែលគាត់ធ្វើដំណើរទៅផ្សាយដំណឹងល្អ។ លោកម៉ាកុសមិនធ្លាប់លំបាកទេ។ ម្ដាយរបស់លោកជាអ្នកមាន ព្រមទាំងជាអ្នកដឹកនាំក្រុមជំនុំនៅទីក្រុងយេរូសាឡិមផង។ ផ្ទះរបស់ម្ដាយលោកយ៉ូហាន-ម៉ាកុស ជាកន្លែងពួកជំនុំថ្វាយបង្គំរៀងរាល់ថ្ងៃបរិសុទ្ធ។ នៅពេលដែលលោកធ្វើដំណើរមកដល់ស្រុកពើកា រួចហើយចូលទៅដល់បេះដូងនៃទ្វីបអាស៊ីចុងខាងលិច

លោកឃើញមានអ្នកថ្វាយបង្គំរូបព្រះ និងគ្រោះថ្នាក់ដែលលោកត្រូវឆ្លងកាត់ ជម្ងឺខ្វះម្ហូបអាហារ។ លោកគិតថា ប្រហែលជាព្រះជាម្ចាស់មិនត្រាស់ហៅលោកអោយធ្វើជាបេសកជនទេ។ លោកសម្រេចចិត្តត្រឡប់មកផ្ទះវិញទៅ។

ក្រោយមកទៀត លោកយ៉ូហាន-ម៉ាកុសចង់ចូលរួមដំណើរជាមួយនឹងសាវ័កប៉ុលម្តងទៀត។ លោកប៉ុលបដិសេធមិនព្រមទទួលអោយលោកយ៉ូហាន-ម៉ាកុសរួមដំណើរទេ។ លោកប៉ុលនិងលោកបាណាបាសបានចែកផ្លូវគ្នា ដោយសារតែបញ្ហារបស់លោកយ៉ូហាន-ម៉ាកុស។ ក្រោយមកទើបសាវ័កប៉ុលដឹងខ្លួនថា កិរិយារបស់លោកខុសទេ។ ព្រះជាម្ចាស់មិនបានបោះបង់ចោលលោកយ៉ូហាន-ម៉ាកុស ដោយសារតែលោកបរាជ័យម្តងរួចហើយនោះទេ។ ចំណែកឯព្រះអម្ចាស់ទ្រង់តែងតែប្រទានអោយយើងមានឱកាសជាច្រើនដង។ ព្រះជាម្ចាស់ប្រទានអោយយ៉ូហាន-ម៉ាកុស មានឱកាសម្តងទៀត បានជាលោកអាចងើបឡើងជាមនុស្សធំពេញវ័យ។ ពេលមុនសាវ័កប៉ុលទទួលទៅនៅជាមួយព្រះអង្គ លោកបានសរសេរសំបុត្រប្រាប់ដល់លោកធីម៉ូថេជាសិស្សរបស់លោកថា "មានតែលោកលូកាប៉ុណ្ណោះទេ ដែលនៅជាមួយនឹងខ្ញុំ ចូរឱ្យអ្នកនាំម៉ាកុសទៅជាមួយផង ដ្បិតគាត់ជាអ្នកមានប្រយោជន៍ក្នុងការងារខ្ញុំ" (២ធីម៉ូថេ៤:១១)។ លោកយ៉ូហាន-ម៉ាកុសជាអ្នកកត់ត្រាគម្ពីរដំណឹងល្អម៉ាកុស។ អរព្រះគុណដល់ព្រះជាម្ចាស់ដែលទ្រង់ផ្តល់ឱកាសម្តងទៀត ដល់លោកយ៉ូហាន-ម៉ាកុស ដ្បិតឥឡូវនេះលោកបានធំពេញវ័យហើយ។

## សាវ័កប៉ុលអធិប្បាយនៅក្រុងអាន់ទីយ៉ូក

**[14]តែគេចេញពីពើកា ដើរកាត់ទៅឯអាន់ទីយ៉ូក នៅស្រុកពីស៊ីឌា ក៏ចូលទៅអង្គុយក្នុងសាលាប្រជុំ នៅថ្ងៃឈប់សំរាក [15]ក្រោយការដែលអានមើលក្រិត្យវិន័យ នឹងគម្ពីរពួកហោរាហើយ នោះមេសាលាក៏ប្រើមនុស្ស ឲ្យទៅប្រាប់ថា បងប្អូនអើយ បើមានសេចក្តីអ្វីនឹងទូន្មានដល់ពួកជន នោះសូមបងប្អូនមានប្រសាសន៍ចុះ (កិច្ចការ១៣:១៤-១៥)។**

ឥឡូវ សាវ័កប៉ុលចូលទៅសាលាប្រជុំរបស់សាសន៍យូដាទៀតហើយ។ សាសន៍យូដានាំគ្នារស់នៅបែកខ្ញែកគ្នា សព្វទីកន្លែងនៅក្នុងរាជាណាចក្ររ៉ូម។ ទីណាដែលគេទៅដល់ គេតែងតែសង់សាលាប្រជុំដើម្បីនាំគ្នាថ្វាយបង្គំ។ បើគាប់ជួនជាមានភ្ញៀវដែលមកពីទីក្រុងយេរូសាឡិម គឺចង់អោយភ្ញៀវទាំងនោះធ្វើទីបន្ទាល់ ឬក៏បង្ហាត់បង្រៀនព្រះបន្ទូល។ ឆ្លៀតឱកាសនោះ សាវ័កប៉ុលផ្សាយដំណឹងល្អ។ នៅពេលដែលគេហៅលោក លោកក៏និយាយតាមសំណូមរបស់គេទៅ។ សេចក្តីអធិប្បាយរបស់សាវ័កប៉ុល ដែលលោកបង្រៀននៅក្នុងទីក្រុងអាន់ទីយ៉ូក ខេត្តពីស៊ីឌា ជាសេចក្តីបង្រៀនដែលមានខ្លឹមសារជ្រាលជ្រៅជាទីបំផុត។ នៅពេលដែលគេសូមអោយសាវ័ក

ប៉ុលនិយាយ លោកក៏ចាប់ផ្ដើមនិយាយពីដំណឹងល្អតែម្ដង។ ការនោះជាមូលហេតុ ដែលលោកធ្វើដំណើរមកទីនេះ។

**លំដាប់នោះ ប៉ុលក៏ក្រោកឡើង ធ្វើគ្រឿងសំគាល់នឹងដៃ និយាយថា ពួកសាសន៍អ៊ីស្រាអែល នឹងអស់អ្នកដែលកោតខ្លាចដល់ព្រះអើយ សូមស្តាប់ចុះ (កិច្ចការ១៣:១៦)។**

បើតាមសេចក្តីផ្តើមនៃការអធិប្បាយរបស់សាវ័កប៉ុល យើងអាចសន្និដ្ឋានថា នៅទីនោះ មិនមែនសុទ្ធតែជាសាសន៍យូដាទេ គឺមានសាសន៍ដទៃខ្លះដែលចូលសាសន៍យូដាផង។

**១៧ ព្រះនៃសាសន៍អ៊ីស្រាអែលយើងនេះ ទ្រង់បានរើសពួកឰយុកោ
យើងរាល់គ្នា ក៏លើកដំកើងសាសន៍យើង ក្នុងកាលដែលគេ
អាស្រ័យនៅស្រុកអេស៊ីព្ទនៅឡើយ រួចទ្រង់នាំគេចេញពីស្រុក
នោះ ដោយព្រះហស្តដ៏មានព្រះចេស្តា ១៨ ហើយទ្រង់បានទ្រាំទ្រ
នឹងកិរិយារបស់គេ នៅទីរហោស្ថាន ក្នុងរវាងប្រហែលជា៤០ឆ្នាំ
១៩ ក្រោយដែលទ្រង់បានបំផ្លាញសាសន៍ទាំង៧ នគរនៅស្រុក
កាណាន នោះក៏ចែកស្រុករបស់គេដល់ពួកឰយុកោយើងដោយ**

**ចាប់ឆ្នោត [២០]ក្រោយការទាំងនោះមក ទ្រង់ប្រទានឱ្យមាន**
**ចៅហ្វាយក្នុងរវាងប្រហែលជា៤៥០ឆ្នាំ ដរាបដល់គ្រាហោរា**
**សាំយូអែល (កិច្ចការ១៣:១៧-២០)។**

សាវ័កប៉ុលចាប់ផ្ដើមសេចក្ដីបង្រៀនរបស់លោក ដូចលោកស្ទេផានអធិប្បាយដែរ។ លោកចាប់ផ្ដើមជាមួយនឹងប្រវត្តិសាស្ត្ររបស់សាសន៍អ៊ីស្រាអែល។

**[២១]នោះគេសូមឱ្យមានស្តេច រួចព្រះទ្រង់តាំងសូល ជាបុត្រគីស**
**ក្នុងពូជអំបូរបេនយ៉ាមីន ឱ្យធ្វើជាស្តេចលើគេ នៅរវាង៤០ឆ្នាំ**
**[២២]កាលដកស្តេចនោះចេញហើយ នោះទ្រង់លើកដាវីឌតាំងឡើង**
**ជាស្តេចវិញ ក៏ធ្វើបន្ទាល់ពីស្តេចដាវីឌថា "អញរកបានដាវីឌ កូន**
**អ៊ីសាយ ជាទីគាប់ចិត្តដល់អញ ដែលនឹងធ្វើតាមចិត្តអញគ្រប់**
**ជំពូក" [២៣]គឺពីព្រះវង្សាស្តេចនោះហើយ ដែលព្រះបានបង្កើត**
**ព្រះអង្គសង្គ្រោះ១អង្គ ដល់សាសន៍អ៊ីស្រាអែល តាមសេចក្តីសន្យា**
**គឺជាព្រះយេស៊ូវ (កិច្ចការ១៣:២១-២៣)។**

បន្ទាប់ពីលោកបានពន្យល់ដល់សាសន៍យូដា អំពីប្រវត្តិសាស្ត្ររបស់សាសន៍អ៊ីស្រាអែលហើយ លោកក៏ចាប់ផ្ដើមពន្យល់អំពីអង្គព្រះយេស៊ូវដែលជាអង្គសង្គ្រោះ

របស់មនុស្សលោក។

**[២៤]តែមុនដែលទ្រង់យាងមក នោះលោកយ៉ូហានបានប្រកាស
ប្រាប់ពីបុណ្យជ្រមុជទឹក ខាងឯការប្រែចិត្ត ដល់សាសន៍
អ៊ីស្រាអែលទាំងអស់គ្នាជាស្រេចហើយ [២៥]កាលលោកយ៉ូហាន
កំពុងតែធ្វើសំរេចការងារនោះ លោកមានប្រសាសន៍ថា តើអ្នក
រាល់គ្នាស្មានថា ខ្ញុំជាអ្នកណា ខ្ញុំមិនមែនជាព្រះអង្គនោះទេ
តែមើល ព្រះអង្គនោះយាងមកក្រោយខ្ញុំ ខ្ញុំមិនគួរនឹងស្រាយ
ខ្សែស្បែកជើងទ្រង់ផង [២៦]ឱបងប្អូន ជាកូនចៅពូជអ័ប្រាហាំ
នឹងអស់អ្នកក្នុងពួកអ្នករាល់គ្នា ដែលកោតខ្លាចដល់ព្រះអើយ
ទ្រង់បានផ្ញើព្រះបន្ទូលពីសេចក្តីសង្គ្រោះនេះ មកដល់អ្នករាល់គ្នា
(កិច្ចការ១៣:២៤-២៦)។**

អ្នកស្រុកនៅក្រុងអាន់ទីយ៉ូក ធ្លាប់ឮដំណឹងអំពីលោកយ៉ូហាន-បាទីស្ទ។ ឥឡូវ សាវ័កប៉ុលមានប្រសាសន៍អំពីសាច់រឿង ដែលជ្រៅជាងរឿងដែលអ្នកស្រុកធ្លាប់ដឹងរួចហើយ។

**[២៧]ដ្បិតដោយព្រោះពួកមនុស្សនៅក្រុងយេរូសាឡិម ព្រមទាំងពួក**

**មេរបស់គេមិនបានស្គាល់ទ្រង់ទេ ក៏មិនបានយល់សេចក្ដីទំនាយ**
**របស់ពួកហោរា ដែលគេមើលរាល់តែថ្ងៃឈប់សំរាកដែរ បានជា**
**គេធ្វើសំរេចតាមសេចក្ដីទំនាយនោះឯង ដោយគេបានកាត់**
**ទោសដល់ទ្រង់ ២៨ ហើយទោះបើគេរកហេតុអ្វីនឹងសំឡាប់ទ្រង់**
**មិនបានក៏ដោយ គង់តែគេសូមអង្វរដល់លោកពីឡាត់ ឱ្យបាន**
**សំឡាប់ទ្រង់ដែរ (កិច្ចការ១៣:២៧-២៨)។**

សាវ័កប៉ុលបរិយាយអំពីប្រវត្តិសាស្ត្រ រួចហើយលោកចង្អុលបង្ហាញថា ព្រះអម្ចាស់យេស៊ូវដែលទ្រង់យាងមកប្រសូតនោះ គឺទ្រង់ប្រសូតដើម្បីបំពេញអស់ទាំងសេចក្ដីទំនាយនានា ដែលពួកហោរាទាយទុក។ សាសន៍យូដាចូលចិត្តនិយាយអំពីទំនាយដែលថាព្រះសង្គ្រោះយាងមកណាស់ តែគេមិនយល់អំពីបទទំនាយដែលគេនិយាយនោះទេ។

**២៩ ក្រោយដែលគេធ្វើសំរេចគ្រប់សេចក្ដី ដែលចែងទុកពីទ្រង់រួច**
**ហើយ នោះគេក៏យកទ្រង់ចុះពីឈើឆ្កាងមកបញ្ចុះក្នុងផ្នូរ ៣០ តែ**
**ព្រះបានប្រោសឱ្យទ្រង់មានព្រះជន្មរស់ពីស្លាប់ឡើងវិញ ៣១ ហើយ**
**ទ្រង់លេចមក ឱ្យពួកអ្នកដែលបានឡើងពីស្រុកកាលីឡេ មកឯ**
**ក្រុងយេរូសាឡិមជាមួយនឹងទ្រង់ បានឃើញជាយូរថ្ងៃ អ្នកទាំង**

**នោះជាសួរបន្ទាល់ពីទ្រង់ដល់ពួកជនទាំងឡាយ (កិច្ចការ១៣: ២៩-៣១)។**

សាវ័កប៉ុលអធិប្បាយដំណឹងល្អរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ឯដំណឹងល្អដែលលោកអធិប្បាយនោះ គឺជាបេះដូងនៃព្រះគម្ពីរសញ្ញាថ្មីទាំងមូល។ ដំណឹងល្អដែលសាវ័កប៉ុលអធិប្បាយ គឺសេចក្តីសុគតនិងការរស់ឡើងវិញ នៃព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ សេចក្តីនេះ គឺជាបេះដូងនៃដំណឹងល្អ។ បើលោកមិនអធិប្បាយអំពីដំណើរនោះទេ លោកអ្នកមិនបានផ្សាយដំណឹងល្អឡើយ។ សាវ័កប៉ុលនិងសាវ័កពេត្រុស អធិប្បាយសេចក្តីដូចគ្នា គឺលោកសង្កត់ធ្ងន់ទៅលើសេចក្តីសុគត និងការរស់ឡើងវិញរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ សេចក្តីអធិប្បាយរបស់លោកទាំងពីរមិនមានទំនាស់អ្វីជាមួយនឹងគ្នាទេ។

**៣២ យើងខ្ញុំក៏ប្រាប់ដំណឹងល្អនេះ ដល់អ្នករាល់គ្នា គឺជាសេចក្តីសន្យាដែលបានតាំងនឹងពួកឰយុកោយើងថា ៣៣ ព្រះបានធ្វើសំរេចតាមសេចក្តីសន្យាទ្រង់ ដល់យើងជាពូជនៃពួកឰយុកោនោះហើយ ដោយទ្រង់បានប្រោសឲ្យព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ ដូចមានសេចក្តីចែងទុកមក ក្នុងទំនុកដំកើងបទទី២ថា "ឯងជាកូនអញ អញបានបង្កើតឯងនៅថ្ងៃនេះ" (កិច្ចការ១៣:៣២-៣៣)។**

សេចក្តីដែលចែងនៅក្នុងខខាងលើ ដកស្រង់ចេញពីក្នុងគម្ពីរទំនុកដំកើង ២:៧។ បទគម្ពីរនេះសំដៅទៅលើព្រះអម្ចាស់យេស៊ូវ រស់ពីសុគតឡើងវិញ។

> **[៣៤] ហើយដែលព្រះបានប្រោសឱ្យទ្រង់មានព្រះជន្មរស់ពីស្លាប់ឡើងវិញ ដើម្បីមិនឱ្យទ្រង់ត្រឡប់ទៅឯសេចក្តីពុករលួយទៀតឡើយ នោះទ្រង់មានបន្ទូលដូច្នេះថា "អញនឹងផ្តល់សេចក្តីមេត្តាករុណាស្មោះត្រង់ ដែលឱ្យដល់ដាវីឌ ដល់ឯងរាល់គ្នាដែរ" [៣៥] ហេតុដូច្នេះ បានជាទ្រង់មានបន្ទូលក្នុងបទ១ទៀតថា "ទ្រង់មិនទុកឱ្យអ្នកបរិសុទ្ធនៃទ្រង់ ឃើញសេចក្តីពុករលួយឡើយ" (កិច្ចការ១៣: ៣៤-៣៥)។**

សាវ័កប៉ុលពង្រីកខ្លឹមសារនៃការរស់ឡើងវិញ របស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។

> **[៣៦] រីឯហ្លួងដាវីឌ កាលទ្រង់បានធ្វើការងារចំពោះមនុស្ស ជំនាន់ទ្រង់ តាមព្រះហឫទ័យព្រះ រួចស្រេចហើយ នោះក៏ផ្ទំលក់ទៅ ហើយបានប្រមូលទៅមូលនឹងពួកឰយុកោទ្រង់ ក៏ឃើញសេចក្តីពុករលួយដែរ [៣៧] តែព្រះអង្គនោះ ដែលព្រះបានប្រោសឱ្យរស់ឡើងវិញ ទ្រង់មិនបានឃើញសេចក្តីពុករលួយឡើយ [៣៨] ដូច្នេះ**

**អ្នករាល់គ្នា ជាបងប្អូនអើយ សូមជ្រាបថា ដែលមានសេចក្តីប្រោសឱ្យរួចពីបាប បានប្រកាសប្រាប់ដល់អ្នករាល់គ្នា នោះគឺដោយសារព្រះអង្គនោះឯង [៣៩]មួយទៀត ដោយសារទ្រង់ អស់អ្នកណាដែលជឿ បានរាប់ជាសុចរិត រួចពីគ្រប់ការទាំងអស់ ដែលពុំអាចនឹងបានរាប់ជាសុចរិត ដោយសារក្រឹត្យវិន័យលោកម៉ូសេបានឡើយ (កិច្ចការ១៣:៣៦-៣៩)។**

ឥឡូវនេះ លោកសម្រួចចំណុចរបស់លោកបន្តិចៗម្តង។ លោកពន្យល់ថា ការជឿលើសេចក្តីសុគតនឹងការរស់ឡើងវិញនៃព្រះអម្ចាស់យេស៊ូវ មានសារៈសំខាន់សម្រាប់ព្រលឹងរបស់មនុស្សគ្រប់រូប។ លុះលោកសម្រួចចំណុចនេះរួចហើយ លោកទូន្មានដល់អ្នកស្តាប់ថា លោកអ្នកត្រូវសម្រេចចិត្តជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទក្នុងពេលនេះចុះ។

**[៤០]ដូច្នេះ ត្រូវប្រយ័ត្ន ក្រែងអ្នករាល់គ្នាកើតមានសេចក្តី ដែលពួកហោរាបានទាយទុកថា [៤១]"នែ អស់អ្នកដែលមើលងាយអើយ ចូរភាំងក្តួល ហើយវិនាសទៅចុះ ដ្បិតអញធ្វើការ១នៅជំនាន់ឯងរាល់គ្នា គឺជាការដែលឯងរាល់គ្នាមិនព្រមជឿឡើយ ទោះបើមានគេប្រាប់មកឯងរាល់គ្នាក៏ដោយ" (កិច្ចការ១៣:៤០-៤១)។**

លោកធ្វើការអំពាវនាវដល់អ្នកស្តាប់ទាំងអស់ សូមកុំអោយបដិសេធដំណឹងល្អដែលលោកអធិប្បាយនេះឡើយ។

**កាលពួកសាសន៍យូដា បានចេញពីសាលាប្រជុំទៅហើយ នោះពួកសាសន៍ដទៃ ក៏សូមឱ្យប៉ុលអធិប្បាយតាមសេចក្តីទាំងនោះ នៅថ្ងៃឈប់សំរាកមួយក្រោយទៀត (កិច្ចការ១៣:៤២)។**

ក្រោយដែលបានឮសេចក្តីបង្រៀនរបស់សាវ័កប៉ុលហើយ ពួកសាសន៍ដទៃសូមអោយលោកអធិប្បាយរឿងដដែលនេះនៅថ្ងៃបរិសុទ្ធលើកក្រោយ។

**[៤៣]កាលពួកអ្នកប្រជុំនោះបានបែកចេញពីគ្នាទៅ នោះមានពួកសាសន៍យូដា នឹងពួកចូលសាសន៍ជាច្រើនដែលមកថ្វាយបង្គំ គេដើរតាមប៉ុល នឹងបាណាបាស ដែលទូន្មានឱ្យគេកាន់ខ្ជាប់ក្នុងព្រះគុណនៃព្រះ [៤៤]ដល់ថ្ងៃឈប់សំរាកក្រោយ នោះពួកអ្នកក្រុងស្ទើរតែទាំងអស់ ក៏មកប្រជុំគ្នា ដើម្បីនឹងស្តាប់ព្រះបន្ទូល (កិច្ចការ ១៣:៤៣-៤៤)។**

ក្នុងរយៈពេលពេញមួយសប្តាហ៍ មនុស្សនៅទីក្រុងប៉ាផុស នាំគ្នាពិចារណា

ហើយចេះតែនិយាយអំពីដំណឹងល្អដែលសាវ័កប៉ុលទើបនឹងបង្រៀន។ ដូច្នេះ ហើយបាន ជានៅថ្ងៃឈប់សម្រាកលើកក្រោយ មនុស្សស្ទើរទាំងអស់នៅក្នុងទីក្រុងនាំគ្នាទៅសាលាប្រជុំ ដើម្បីស្តាប់សេចក្តីអធិប្បាយរបស់សាវ័កប៉ុលម្តងទៀត។

**តែកាលពួកសាសន៍យូដាបានឃើញមនុស្សទាំងហ្វូងដូច្នេះ នោះ កើតមានចិត្តពេញដោយសេចក្តីច្រណែន ហើយក៏ឆ្លើយទទឹង ទាស់នឹងសេចក្តី ដែលប៉ុលអធិប្បាយនោះ ទាំងជំនះ ហើយ ប្រមាថផង (កិច្ចការ១៣:៤៥)។**

ឥឡូវនេះ បន្ទាប់ពីឃើញថា មនុស្សជាច្រើនជឿដល់ដំណឹងល្អ អ្នកដឹកនាំសាសនានៅក្នុងសាលាប្រជុំ គេធ្វើសកម្មភាពប្រឆាំងជាមួយនឹងសាវ័កប៉ុល ហើយនឹងបាណាបាសចំមុខតែម្តង។

**៤៦ ប៉ុន្តែប៉ុល នឹងបាណាបាសនិយាយដោយក្លាហានថា មុខគួរឱ្យយើងខ្ញុំថ្លែងប្រាប់ព្រះបន្ទូល ដល់អ្នករាល់គ្នាជាមុនដំបូង ប៉ុន្តែដោយព្រោះអ្នករាល់គ្នាបោះបង់ចោលព្រះបន្ទូលនោះ ហើយជំនុំជំរះកាត់ទោសដល់ខ្លួនឯងថា មិនគួរនឹងទទួលបានជីវិតដ៏នៅអស់កល្បជានិច្ចនោះទេ ហេតុដូច្នេះបានជាយើងខ្ញុំបែរទៅឯពួក**

> **សាសន៍ដទៃវិញ ៤៧ "ដ្បិតព្រះអម្ចាស់ ទ្រង់បានបង្គាប់មកយើងខ្ញុំ**
> **ដូច្នេះថា "អញបានតាំងឯងសំរាប់ជាពន្លឺដល់សាសន៍ដទៃ ដើម្បី**
> **ឲ្យឯងបានសំរាប់ជាសេចក្តីសង្គ្រោះដល់ចុងផែនដីបំផុត" ៤៨ "កាល**
> **ពួកសាសន៍ដទៃបានឮដូច្នោះ នោះគេមានសេចក្តីអំណរ ហើយ**
> **ក៏សរសើរព្រះបន្ទូលនៃព្រះអម្ចាស់ ចំណែកអស់អ្នកដែលត្រូវបាន**
> **ជីវិតអស់កល្បជានិច្ច នោះក៏បានជឿ ៤៩ "ឯព្រះបន្ទូលនៃព្រះអម្ចាស់**
> **បានផ្សាយសុសសាយទូទៅពេញក្នុងស្រុកនោះ (កិច្ចការ១៣:**
> **៤៦-៤៩)។**

ហេតុការណ៍ដដែលនេះ កើតឡើងជាយូរឆ្នាំមកហើយ។ ដំណឹងល្អត្រូវទៅដល់សាសន៍យូដាជាមុនសិន។ លុះដល់សាសន៍នេះបដិសេធ សាសន៍ដទៃមានឱកាសឮដំណឹងល្អរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។

> **តែពួកសាសន៍យូដាគេញុះញង់ពួកស្ត្រីអ្នកមុខអ្នកការ ដែលមកថ្វាយបង្គំ នឹងពួកអ្នកធំនៅក្នុងទីក្រុងនោះ បណ្តាលឱ្យមានសេចក្តីបៀតបៀន ដល់ប៉ុល នឹងបាណាបាស ក៏ដេញអ្នកទាំង២នោះចេញពីស្រុកគេទៅ (កិច្ចការ១៣:៥០)។**

ឥឡូវ គេនាំគ្នាបណ្ដេញលោកបាណាបាស ហើយនឹងសាវ័កប៉ុលចេញពីទីក្រុងរបស់គេ។

> **[៥១]ដូច្នេះ អ្នកទាំង២ក៏រលាស់ធូលីដីពីជើងចេញទាស់នឹងគេ រួចចេញទៅឯក្រុងអ៊ីកូនាម [៥២]ឯពួកសិស្ស គេមានចិត្តពេញដោយសេចក្ដីអំណរ ហើយនឹងព្រះវិញ្ញាណបរិសុទ្ធ (កិច្ចការ១៣:៥១-៥២)។**

អ្នកដែលបានជឿដល់ព្រះអម្ចាស់យេស៊ូវ មានចិត្តរីករាយសប្បាយ ពីព្រោះគេបានពេញជាព្រះវិញ្ញាណបរិសុទ្ធ។

យើងស្លេះការសិក្សាគម្ពីរកិច្ចការត្រឹមណោះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្ដម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ដើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!"